# ការរកឃើញរោគមហារីកពោះវៀនដំបូង

The Cancer Council South Australia

**រោគមហារីកពោះវៀន (គេក៏ស្គាល់ថា colorectal cancer) គឺជារោគមហារីកដ៏សាមញ្ញដែលកើតមានច្រើនជាងគេបំផុតនៅប្រទេសអូស្ត្រាលី (ក្រៅពីរោគមហារីកស្បែកសាមញ្ញ) ។ គេអាចរកឃើញច្រើននៅដំណាក់ការដំបូងនៅពេលដែលការព្យាបាលប្រហែលជាអាចធ្វើឲ្យជម្ងឺនេះជាសះស្បើយបាន ។ វាក៏មានវិធានការខ្លះៗដែលលោកអ្នកអាចចាត់ការបាន ដើម្បីជួយបន្ថយគ្រោះថ្នាក់នៃរោគមហារីកពោះវៀនរបស់លោកអ្នក ។**

## តើពោះវៀនជាអ្វី?

ពោះវៀនគឺជាភាគនៃបំពង់រំលាយអាហារមួយវែងបំផុត (digestive tract) ។ វាមាន ២ ផ្នែក ៖

- ពោះវៀនតូច, ជាកន្លែងដែលស្រូបយកម្ហូបអាហារចូល ។
- ពោះវៀនធំ, ជាកន្លែងដែលស្រូបយកទឹកនិងអំបិលចូល ។ ពោះវៀនធំគឺមាន ២ ភាគ-ពោះវៀនធំ (colon)

ហើយនិងចុងពោះវៀន (rectum ) ។

## តើរោគមហារីកពោះវៀនជាអ្វី?

រោគមហារីកពោះវៀនគឺជាសាច់ដុះនៃមហារីកដែលតាមធម្មតាចាប់ផ្ដើមនៅលើទ្រនាប់នៃពោះវៀនធំ ។ វាអាចរីកធំនៅទីនោះយ៉ាងយូរមុននឹងវារាលដាលទៅភាគផ្សេងៗទៀតនៃដងខ្លួន (metastasising) ។

ហេតុនេះហើយបើការរកឃើញរោគមហារីកពោះវៀននៅដំណាក់ការដំបូងកាន់តែបានឆាប់ សំណាងនៃការព្យាបាលឲ្យជាសះស្បើយ ក៏កាន់តែល្អប្រសើរឡើងដែរ ។ ភព្វសំណាងនៃការជាសះស្បើយ គឺមាន ៩០% ប្រសិនបើរោគមហារីកពោះវៀនត្រូវបានគេរកឃើញនៅដំណាក់ការដំបូង ។

## តើរោគមហារីកពោះវៀនមានជាទូទៅយ៉ាងដូចម្ដេចដែរ?

រោគមហារីកពោះវៀនគឺជារោគមហារីកដែលកើតមានច្រើនជាងគេបំផុត ហើយប៉ះពាល់ដល់បុរស និងស្ត្រីនៅរដ្ឋអូស្ត្រាលីខាងត្បូង ។ ប្រជាជនចំនួនជាងមួយពាន់នាក់ត្រូវបានគេធ្វើរោគវិនិច្ឆ័យក្នុងមួយឆ្នាំៗ ។

## តើនរណាអាចមានគ្រោះថ្នាក់ដោយរោគមហារីកពោះវៀន?

រោគមហារីកពោះវៀនអាចកើតមានគ្រប់អាយុកាល, ក៏ប៉ុន្តែគ្រោះថ្នាក់មានកាន់តែច្រើនឡើងទៀត ប្រសិនបើលោកអ្នកមានអាយុលើសពី ៥០ឆ្នាំ ។

គ្រោះថ្នាក់របស់លោកអ្នកក្នុងការកើតរោគមហារីកពោះវៀនក៏កាន់តែកើនឡើងទៀត ប្រសិនបើ ៖

- លោកអ្នកមានប្រវត្តិគ្រួសារដែលមានរោគមហារីកពោះវៀន ។
- លោកអ្នកមានជម្ងឺរលាកពោះវៀនខ្លាំង(ulcerative colitis or Crohn's colitis)ជាង៨ឆ្នាំមកហើយ។ ប្រសិនបើកត្តាទាំងអស់នេះទាក់ទិនចំពោះលោកអ្នក, សូមនិយាយប្រាប់វេជ្ជបណ្ឌិតលោកអ្នកអំពីគ្រោះថ្នាក់នៃរោគមហារីកពោះវៀនរបស់លោកអ្នក ។

## រោគសញ្ញានៃរោគមហារីកពោះវៀន

មិនមែនរោគមហារីកពោះវៀនទាំងអស់ទេដែលបង្ហាញរោគសញ្ញា ក៏ប៉ុន្តែលោកអ្នកគួរជួបវេជ្ជបណ្ឌិតលោកអ្នក ប្រសិនបើលោកអ្នកសង្កេតឃើញអ្វីមួយដូចតទៅនេះ ៖

- ការចេញឈាមនៅគូថរបស់លោកអ្នក ឬសញ្ញាឈាមណាមួយនៅក្រោយបទជើងធំរួច ។
- ការផ្លាស់ប្ដូរមិនឈប់នៃទម្លាប់បទជើងធំ: ដូចជាការបទជើងធំមិនទៀងទាត់ ឬច្រើនដង, ដំណើរទល់លាមកកាន់តែកើនឡើង, និង/ឬ ការទៅបង្គន់ញឹកញាប់ជាងធម្មតា ។
- លោកអ្នកមានអារម្មណ៍ដូចបទជើងធំមិនអស់សោះ ។
- ការអស់កម្លាំង, ខ្សោយ ឬដកដង្ហើមមិនដល់គ្នាដែលមិនអាចពន្យល់បាន ។ ទាំងអស់នេះប្រហែលមកពីកង្វះឈាមក្រហមដែលបណ្ដាលមកពីការខ្វះជាតិដែក ។ ប្រភេទកង្វះឈាមក្រហមនេះអាចជាហេតុនៃរោគមហារីកពោះវៀន ។
- ការឈឺចុកពោះ ។
- ស្រកទម្ងន់ដោយគ្មានហេតុផលពិតប្រាកដ ។

## បំពង់រំលាយអាហារ




*Khmer*

*Finding Bowel Cancer Early*

ពត៌មានអំពីរោគមហារីកអាចរកបានតាមរយៈអ្នកបកប្រែភាសា ។

សូមទូរស័ព្ទលេខ **13 14 50** ហើយស្នើសុំការបន្តទៅលេខទូរស័ព្ទខាងផ្ដល់ជំនួយរោគមហារីកលេខ **13 11 20**

202 Greenhill Road
Eastwood SA 5063
Telephone (08) 8291 4111
Facsimile (08) 8291 4122
tcc@cancersa.org.au
www.cancersa.org.au

August 2005

# ការរកឃើញរោគមហារីកពោះវៀនដំបូង

The Cancer Council
South Australia

***អ្នកដែលមានអាយុលើសពី ៥០ឆ្នាំ*** គួរប្រយ័ត្នមើលសញ្ញាព្រមាននៃរោគមហារីកពោះវៀន ។ ប្រសិនបើលោកអ្នកមានរោគសញ្ញាណាមួយ, សូមជួបវេជ្ជបណ្ឌិតរបស់លោកអ្នកដែលនឹងបញ្ជូនលោកអ្នកទៅធ្វើតេស្តណាមួយដែលលោកអ្នកប្រហែលជាត្រូវការ ។ តាមធម្មតាវាមានការពន្យល់ងាយៗមួយ, ក៏ប៉ុន្តែប្រសិនបើវាជារោគមហារីកពោះវៀនមែន, វាជាការល្អបំផុតដែលគេរកឃើញវាមុន ។

## ការឆ្លុះមើលរោគមហារីកពោះវៀន

ការឆ្លុះមើលរោគមហារីកពោះវៀនទាក់ទិននឹងការធ្វើតេស្តប្រជាជនដែលគ្មានរោគសញ្ញាដ៏ជាក់ស្តែងនៃរោគមហារីកពោះវៀនណាមួយឡើយ ។ ការឆ្លុះមើលដោយធ្វើតេស្តឈាមនៅក្នុងលាមក (Faecal Occult Blood Test )

ត្រូវបានគេឲ្យឱវាទចំពោះប្រជាជនដែលមានសុខភាពល្អ ហើយនិងមានអាយុលើសពី ៥០ឆ្នាំ ។

## តេស្តឈាមនៅក្នុងលាមក (FOBT)

FOBTគឺជាតេស្តងាយៗមួយសំរាប់រកសញ្ញាដំបូងនៃរោគមហារីកពោះវៀន ។ វាទាក់ទិននឹងការយកសំណាកលាមក ២ឬ៣ ដងដោយប្រើប្រដាប់សំរាប់តេស្ត ។ គេមកយកសំណាកនេះពីផ្ទះលោកអ្នក ហើយបញ្ជូនវាទៅទីពិសោធន៍សំរាប់ធ្វើតេស្ត។

FOBT នឹងរកមើលឈាមមួយចំនួនតូចបំផុតដែលមាននៅក្នុងលាមកនោះ (ឈាមដែលមិនអាចមើលឃើញដោយភ្នែកលោកអ្នក) ។ ឈាមដែលមាននៅក្នុងលាមកអាចបណ្តាលមកពីសាច់ដុះ (ដុំសាច់ដុះនៅក្នុងពោះវៀនដែលអាចកើតទៅជារោគមហារីក) ឬរោគមហារីកពោះវៀនដែលចេញឈាម ។

ប្រសិនបើគេរកឃើញឈាមនៅក្នុងលាមក, គេត្រូវការធ្វើតេស្តថែមទៀតដើម្បីរកមើលអ្វីដែលបណ្តាលឲ្យចេញឈាម ។ សូមចាំថា, រោគមហារីកពោះវៀនអាចជាសះស្បើយបានច្រើន (៩០%) ប្រសិនបើគេរកឃើញនៅដំណាក់ការមុនដំបូង ។ ហើយសាច់ដុះដែលគេរកឃើញតាមរយៈ FOBT នោះ, ក៏គេអាចយកវាចេញនៅមុនពេលដែលវាអាចកើតទៅជារោគមហារីក ។

## តើខ្ញុំអាចធ្វើ (FOBT) នៅទីណាបាន?

បុរសនិងស្ត្រីដែលមានអាយុលើសពី ៥០ឆ្នាំទៅ គួរតែជួបវេជ្ជបណ្ឌិតរបស់ខ្លួនស្តីពី (FOBT) រៀងរាល់ពេល ២ឆ្នាំម្តងៗ ។

## ការបន្ថយគ្រោះថ្នាក់នៃរោគមហារីកពោះវៀន

លោកអ្នកអាចជួយបន្ថយគ្រោះថ្នាក់រោគមហារីកពោះវៀនរបស់លោកអ្នកបានដោយ ៖

- ទទួលទានអាហារដែលធ្វើឲ្យមានសុខភាពល្អ, រាប់បញ្ចូលបន្លែនិងផ្លែឈើឲ្យបានច្រើនហើយ និងខ្លាញ់តិចតួចបំផុត ។
- រក្សាទម្ងន់ខ្លួនដែលផ្តល់សុខភាពល្អ
- ហាត់ប្រាណឲ្យទៀងទាត់
- កុំពិសារបារី ។

ដោយធ្វើតាមឱវាទទាំងនេះ, វាមិនមានន័យថាលោកអ្នកនឹងមិនមានរោគមហារីកពោះវៀនសោះទេ, ក៏ប៉ុន្តែវាអាចជួយបន្ថយគ្រោះថ្នាក់របស់លោកអ្នកហើយនិងបានប្រយោជន៍ខាងសុខភាពឯទៀតផងដែរ ។

**Khmer**

*Finding Bowel Cancer Early*

ពត៌មានអំពីរោគមហារីកអាចរកបានតាមរយៈអ្នកបកប្រែភាសា ។

សូមទូរស័ព្ទលេខ **13 14 50** ហើយស្នើសុំការបន្តទៅលេខទូរស័ព្ទខាងផ្តល់ជំនួយរោគមហារីកលេខ **13 11 20**

202 Greenhill Road
Eastwood SA 5063
Telephone (08) 8291 4111
Facsimile (08) 8291 4122
tcc@cancersa.org.au
www.cancersa.org.au

August 2005